# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៣២ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ជាសេនាធិការជូនរាជរដ្ឋាភិបាលលើសកម្មភាពរបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ដែលសរសេរជាអក្សរកាត់ថា លេខាធិការដ្ឋាន **ក.រ.ម**។

**មាត្រា២ .-**

លេខាធិការដ្ឋាន **ក.រ.ម** មានទីតាំងស្ថិតនៅក្នុងទីស្តីការគណៈរដ្ឋមន្ត្រី។



៤

## ជំពូកទី២
## តួនាទីនិងភារកិច្ច

**មាត្រា៣ .-**

លេខាធិការដ្ឋាន **ក.រ.ម** មានតួនាទីសម្របសម្រួលសកម្មភាពនានារបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ដើម្បីគាំទ្រនិងជំរុញការអនុវត្តកម្មវិធីនយោបាយ យុទ្ធសាស្ត្របញ្ចកោណ គោលនយោបាយ និងកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ព្រមទាំងការដោះស្រាយបញ្ហាប្រឈម សំណើ និងសំណូមពរនានារបស់ប្រជាពលរដ្ឋនៅមូលដ្ឋានប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។

**មាត្រា៤ .-**

លេខាធិការដ្ឋាន **ក.រ.ម** មានភារកិច្ចសំខាន់ៗដូចតទៅ៖

- ផ្តល់គោលការណ៍តម្រង់ទិស គាំទ្រ និងជំរុញក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានដើម្បីលើកកម្ពស់សមត្ថភាពស្ថាប័ននៅមូលដ្ឋាន សំដៅពង្រឹងការទទួលខុសត្រូវ និងភាពជាម្ចាស់របស់មូលដ្ឋានក្នុងការអនុវត្តកម្មវិធីនយោបាយ យុទ្ធសាស្ត្របញ្ចកោណ គោលនយោបាយ និងកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល
- ពិនិត្យនិងលើកយោបល់ជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសម្រេចលើការស្នើសុំចាត់តាំង កែសម្រួល និងផ្លាស់ប្តូរសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន
- ទទួលរបាយការណ៍ពីក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ដើម្បីរៀបចំរបាយការណ៍បូកសរុប និងវាយតម្លៃលទ្ធផលការងារ និងបញ្ហាប្រឈមប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីគោរពរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល
- លើកយោបល់រៀបចំសេចក្តីណែនាំ និងគោលការណ៍នានាពាក់ព័ន្ធក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសម្រេច
- សម្របសម្រួលការងារនានាជាមួយក្រសួង ស្ថាប័ន ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានដើម្បីជំរុញការដោះស្រាយបញ្ហាប្រឈម សំណើ និងសំណូមពរនានារបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន
- សហការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំកិច្ចប្រជុំប្រចាំឆមាស ប្រចាំឆ្នាំ និងកិច្ចប្រជុំនានាតាមការចាំបាច់របស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន
- លើកគម្រោងបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាពដល់មន្ត្រីលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន និងឬមន្ត្រីបង្គោលតាមក្រសួង ស្ថាប័ន លើការងាររបាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន
- សហការ និងគាំទ្រការអនុវត្តការងាររបស់លេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានគ្រប់លំដាប់ថ្នាក់



៤

- ធ្វើបច្ចុប្បន្នភាពសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងប្រសិទ្ធភាពក្នុងការចុះបំពេញការងារតាមមូលដ្ឋាន
- សម្របសម្រួលការងារប្រចាំថ្ងៃរបស់លេខាធិការដ្ឋាន **ក.រ.ម** ស្របតាមការណែនាំរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងការសម្រេចរបស់រាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរាជរដ្ឋាភិបាលប្រគល់ឱ្យ។

## ជំពូកទី៣
## រចនាសម្ព័ន្ធ

**មាត្រា៥ .-**

លេខាធិការដ្ឋាន **ក.រ.ម** ត្រូវដឹកនាំដោយប្រធាន១(មួយ)រូប អមដោយអនុប្រធាន២(ពីរ)រូបជាជំនួយការ។

ប្រធានលេខាធិការដ្ឋាន **ក.រ.ម** គឺជាសមាជិករាជរដ្ឋាភិបាល។

អនុប្រធានលេខាធិការដ្ឋាន **ក.រ.ម** គឺជារដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ។

ប្រធាន អនុប្រធានលេខាធិការដ្ឋាន **ក.រ.ម** ត្រូវបានតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

ប្រធានលេខាធិការដ្ឋាន **ក.រ.ម** ត្រូវមានជំនួយការ១(មួយ)រូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីប្រធានលេខាធិការដ្ឋាន **ក.រ.ម**។

អនុប្រធានលេខាធិការដ្ឋាន **ក.រ.ម** ត្រូវមានជំនួយការ១(មួយ)រូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាន និងត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់ប្រធានលេខាធិការដ្ឋាន **ក.រ.ម**។

**មាត្រា៦ .-**

លេខាធិការដ្ឋាន **ក.រ.ម** មានអង្គភាពចំណុះចំនួន២(ពីរ)ដូចខាងក្រោម៖

- អង្គភាពរដ្ឋបាលសរុប
- អង្គភាពតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពចំណុះលេខាធិការដ្ឋាន **ក.រ.ម** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា៧ .-**

អង្គភាពនីមួយៗ ត្រូវដឹកនាំដោយប្រធាន១(មួយ)រូប អមដោយអនុប្រធាន២(ពីរ)រូប ជាជំនួយការ និងមានបុគ្គលិកមួយចំនួនដើម្បីជួយបំពេញការងារប្រចាំថ្ងៃ។

ប្រធានអង្គភាពមានឋានៈស្មើអគ្គនាយក ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។



9

អនុប្រធានអង្គភាពមានឋានៈស្មើអគ្គនាយករង ត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

អង្គភាពនីមួយៗមានផ្នែកមួយចំនួនជាសេនាធិការ។ ប្រធានផ្នែកមានឋានៈស្មើប្រធាននាយកដ្ឋាន ត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

## ជំពូកទី៤
## បុគ្គលិក

**មាត្រា៨ .-**

លេខាធិការដ្ឋាន **ក.រ.ម** មានបុគ្គលិកជួយការងារប្រចាំថ្ងៃដែលអាចជាមន្ត្រីក្របខណ្ឌមុខងារសាធារណៈនៃទីស្តីការគណៈរដ្ឋមន្ត្រី ឬអាចស្នើសុំបុគ្គលិកជាមន្ត្រីក្របខណ្ឌមុខងារសាធារណៈពីក្រសួង ស្ថាប័នផ្សេងទៀតតាមតម្រូវការជាក់ស្តែង។ មន្ត្រីក្របខណ្ឌមុខងារសាធារណៈនៃក្រសួង ស្ថាប័ន ដែលមកបម្រើការងារក្នុងលេខាធិការដ្ឋាន **ក.រ.ម** ត្រូវចាត់តាំងដោយលិខិតបង្គាប់ការរបស់រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមី។

ក្នុងករណីចាំបាច់ លេខាធិការដ្ឋាន **ក.រ.ម** អាចជ្រើសរើសបុគ្គលិកមិនមែនជាមន្ត្រីក្របខណ្ឌមុខងារសាធារណៈមកបម្រើការងារក្នុងលេខាធិការដ្ឋាន **ក.រ.ម**។

**មាត្រា៩ .-**

បុគ្គលិកជាមន្ត្រីក្របខណ្ឌមុខងារសាធារណៈនៃក្រសួង ស្ថាប័ននានា ដែលត្រូវបានចាត់តាំងឱ្យមកបម្រើការងារក្នុងលេខាធិការដ្ឋាន **ក.រ.ម** ត្រូវបានរក្សានូវមុខតំណែង អតីតភាពការងារ ឋានន្តរស័ក្តិ ថ្នាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗទៀតរបស់ខ្លួននៅអង្គភាពនៃក្រសួង ស្ថាប័នដើមដដែល ហើយពុំចាំបាច់ដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើម ឬផ្ទេរក្របខណ្ឌមកទីស្តីការគណៈរដ្ឋមន្ត្រីឡើយ។

បុគ្គលិកជាមន្ត្រីក្របខណ្ឌមុខងារសាធារណៈនៃក្រសួង ស្ថាប័ន ត្រូវត្រលប់ទៅបំពេញការងារតាមតួនាទីនៅតាមក្រសួង ស្ថាប័នរបស់ខ្លួនវិញ នៅពេលបញ្ចប់ភារកិច្ចក្នុងលេខាធិការដ្ឋាន **ក.រ.ម** ឬអាណត្តិរបស់លេខាធិការដ្ឋាន **ក.រ.ម** ត្រូវបានបញ្ចប់។

**មាត្រា១០ .-**

បុគ្គលិកមិនមែនជាមន្ត្រីក្របខណ្ឌមុខងារសាធារណៈគ្មានសិទ្ធិទាមទារមុខតំណែង ក្របខណ្ឌ អតីតភាពការងារ ប្រាក់សោធននិវត្តន៍ និងឬអត្ថប្រយោជន៍ផ្សេងៗទៀតនៅពេលបញ្ចប់ភារកិច្ចក្នុងលេខាធិការដ្ឋាន **ក.រ.ម**។

## ជំពូកទី៥
## របៀបរបបការងារ

**មាត្រា១១ .-**

ប្រធានលេខាធិការដ្ឋាន **ក.រ.ម** ត្រូវរាយការណ៍ និងស្នើសុំយោបល់ពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការសម្របសម្រួលការងារជាមួយក្រសួង ស្ថាប័ននានា ក្រុមការងារពង្រឹងរដ្ឋាភិបាលចុះមូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។



9

**មាត្រា១២ .-**

លេខាធិការដ្ឋាន **ក.រ.ម** ត្រូវសហការសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានា និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រដល់កិច្ចដំណើរការប្រចាំថ្ងៃរបស់លេខាធិការដ្ឋាន **ក.រ.ម**។

**មាត្រា១៣ .-**

ប្រធានលេខាធិការដ្ឋាន **ក.រ.ម** ដឹកនាំការងារទូទៅរបស់លេខាធិការដ្ឋាន **ក.រ.ម**។

ប្រធានលេខាធិការដ្ឋាន **ក.រ.ម** អាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ដើម្បីដឹកនាំការងារប្រចាំថ្ងៃជំនួសក្នុងឋានៈជាប្រធានស្ដីទីរហូតដល់មានវត្តមានប្រធានលេខាធិការដ្ឋាន **ក.រ.ម**។

អនុប្រធានលេខាធិការដ្ឋាន **ក.រ.ម** ត្រូវបំពេញការងារតាមការបែងចែកប្រគល់ភារកិច្ចពីប្រធានលេខាធិការដ្ឋាន **ក.រ.ម** តាមឋានានុក្រម ហើយត្រូវមានគណនេយ្យភាពចំពោះប្រធានលេខាធិការដ្ឋាន **ក.រ.ម**។

**មាត្រា១៤ .-**

ប្រធាន អនុប្រធានអង្គភាព និងបុគ្គលិកនីមួយៗដែលបម្រើការងារក្នុងលេខាធិការដ្ឋាន **ក.រ.ម** ត្រូវមានការទទួលខុសត្រូវអំពីកិច្ចការរបស់ខ្លួនស្របតាមលិខិតបទដ្ឋានជាធរមាន និងមានគណនេយ្យភាពតាមឋានានុក្រម។

**មាត្រា១៥ .-**

លេខាធិការដ្ឋាន **ក.រ.ម** មានសិទ្ធិប្រើត្រាទីស្ដីការគណៈរដ្ឋមន្ត្រីសម្រាប់ដំណើរការការងារប្រចាំថ្ងៃ។

**មាត្រា១៦ .-**

អាណត្តិរបស់លេខាធិការដ្ឋាន **ក.រ.ម** នឹងត្រូវបញ្ចប់ដោយស្វ័យប្រវត្តិនៅពេលដែលអាណត្តិរបស់រាជរដ្ឋាភិបាលនីតិកាលនីមួយៗនៃរដ្ឋសភាត្រូវបានបញ្ចប់។

## ជំពូកទី៦
## ថវិកា

**មាត្រា១៧ .-**

លេខាធិការដ្ឋាន **ក.រ.ម** មានប្រភពធនធានផ្ដត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី។

## ជំពូកទី៧
## អវសានបញ្ញត្តិ

**មាត្រា១៨ .-**

អនុក្រឹត្យលេខ ៩២ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។



ý

**មាត្រា១៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែ ពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ